**លេខ ១៦៥** **ថ្ងៃពុធ ទី០៧ ខែកញ្ញា ឆ្នាំ២០០៥**

**ព័ត៌មានក្នុងប្រទេស**

# ព្រះមហាក្សត្រប្រោសព្រះរាជទានឱ្យឯកអគ្គរាជទូតថ្មី ប្រទេសអេស្ប៉ាញចូលថ្វាយសារតាំង

*លោក ចង លីមអ៊ី AKP ភ្នំពេញ*

ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា បានសព្វព្រះរាជហឫទ័យប្រោសព្រះបរមរាជានុញ្ញាតឱ្យឯកឧត្តម នូអាន ម៉ានូអែល លូប៉េកាតាល់ ចូលថ្វាយបង្គំគាល់ និងថ្វាយសារតាំងជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពថ្មីរបស់ព្រះរាជាណាចក្រអេស្ប៉ាញប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ។

ព្រះរាជពិធីនេះបានប្រព្រឹត្តទៅយ៉ាងឧឡារិកតាមព្រះរាជពិធីការក្នុងព្រះបរមរាជវាំង កាលពីព្រឹកថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៥ ថ្មីៗនេះ ។

ឯកឧត្តម ឯកអគ្គរាជទូតថ្មី នៃព្រះរាជាណាចក្រអេស្ប៉ាញ បានសំដែងនូវអំណរព្រះគុណយ៉ាងជ្រាលជ្រៅថ្វាយព្រះករុណា ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្រោសព្រះរាជទាននូវព្រះរាជពិធីថ្វាយ និងទទួលសារតាំងនេះប្រកបដោយភាពខ្ពង់ខ្ពស់បំផុត ។ ឯកឧត្តមក៏បានសំដែងនូវសេចក្តីរីករាយដែលបានមកបំពេញភារកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ដែលជាប្រទេសមួយបានគោរព និងអនុវត្តន៍លទ្ធិប្រជាធិបតេយ្យបរិបូណ៌ ប្រកបទៅដោយសុខសន្តិភាព និងមានការអភិវឌ្ឍន៍យ៉ាងល្អប្រសើរ ។

ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី បានសព្វព្រះរាជហឫទ័យ ថ្លែងអំណរគុណចំពោះព្រះរាជាណាចក្រអេស្ប៉ាញដែលបានបញ្ជូនឯកឧត្តម ឯកអគ្គទូតថ្មីដ៏ឧត្តុង្គឧត្តមមកបំពេញបេសកកម្មដ៏ថ្លៃថ្លានៅព្រះរាជាណាចក្រកម្ពុជា សំរាប់អាណត្តិថ្មីនេះជាការដ៏ល្អប្រពៃណាស់ ដែលបង្ហាញពីការរីកចំរើនស្ថិតស្ថេរនៃចំណងសាមគ្គីភាពរវាងប្រទេសទាំងពីរកម្ពុជា-អេស្ប៉ាញកាន់តែរឹងមាំ ។ ព្រះអង្គជឿជាក់ថា ក្រោមការយកចិត្តទុកដាក់អស់ពីកំលាំងកាយចិត្ត នៃឯកឧត្តមក្នុងការបំពេញបេសកកម្មដ៏ឧត្តុង្គឧត្តមនៅកម្ពុជាពិតជាបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការបន្តពង្រឹងមិត្តភាព និងកិច្ចសហប្រតិបត្តិការទ្វេភាគីលើគ្រប់វិស័យ ។

ព្រះករុណា ព្រះមហាក្សត្រ បានថ្លែងកត្តាញ្ញូតាធម៌យ៉ាងជ្រាលជ្រៅផងដែរចំពោះព្រះរាជាណាចក្រអេស្ប៉ាញដែលបានចូលរួមជាមួយបណ្តាប្រទេសសមាគមន៍អឺរ៉ុបក្នុងការបន្តផ្តល់ជំនួយសំខាន់ៗ ជូនព្រះរាជាណាចក្រកម្ពុជាដើម្បីជំរុញដល់ការអភិវឌ្ឍន៍ឱ្យមានភាពរីកចំរើនជាបន្តបន្ទាប់ ។/

# ឯកអគ្គរាជទូតថៃចូលបង្គំគាល់ព្រះមហាក្សត្រកម្ពុជា

*AKP ភ្នំពេញ*

ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ ព្រះអង្គបានសព្វព្រះរាជហឫទ័យ ព្រះបរមរាជានុញ្ញាតឱ្យ ឯកឧត្តម PIYAWAT NIYOMRERKS ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រថៃប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងសហការី ចូលក្រាបថ្វាយបង្គំគាល់នៅប្រាសាទខេមរិន្ទក្នុងព្រះបរមរាជវាំង នាថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០០៩ ។

ឯកឧត្តម ឯកអគ្គរាជទូតថៃ បានសំដែងព្រះរាជគារវកិច្ចគោរពដ៏ខ្ពង់ខ្ពស់បំផុត ថ្វាយព្រះករុណា ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈ និងបានថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការប្រោសព្រះរាជទានដល់ឯកអគ្គរាជទូត និងមន្ត្រីស្ថានទូតថៃបានចូលក្រាបថ្វាយបង្គំគាល់នាឱកាសនេះ ។ ឯកឧត្តម ឯកអគ្គរាជទូតថៃ បានសំដែងនូវសេចក្តីកោតស្ញប់ស្ញែងជាខ្លាំងចំពោះព្រះរាជហឫទ័យទុកដាក់របស់ព្រះករុណា ព្រះមហាក្សត្រកម្ពុជា ចំពោះការរីកចំរើនទំនាក់ទំនងមិតភាពថៃ-កម្ពុជា ។ ឯកឧត្តម ឯកអគ្គរាជទូតថៃ បានសំដែងថ្វាយនូវសេចក្តីស្ងើចសរសើរថែមទៀតនូវរាល់ព្រះរាជកិច្ចដ៏ឧត្តុង្គឧត្តមរបស់ព្រះករុណាក្នុងព្រះរាជកិច្ចបំរើប្រទេសជាតិ និងប្រជារាស្ត្រកម្ពុជាក្នុងព្រះរាជសកម្មភាពមនុស្សធម៌ នៃការជួយស្រោចស្រង់ជីវភាពរបស់ប្រជារាស្ត្រទីទ័លក្រ ជួបប្រទះនូវគ្រោះធម្មជាតិ ដោយទទួលបាននូវមហាកិត្តិយសដ៏ខ្ពង់ខ្ពស់ទាំងនៅលើឆាកជាតិ និងអន្តរជាតិ ។ នៅក្នុងឱកាសនោះ ឯ.ឧ ឯកអគ្គរាជទូតថៃបានថ្វាយនូវដង្វាយជាទឹកប្រាក់ចំនួន ៥សែនបាត ស្មើនឹង ១២.៨៨៧ដុល្លារអាមេរិក ថ្វាយព្រះករុណា ព្រះមហាក្សត្រកម្ពុជា ។

ឯកឧត្តម ឯកអគ្គរាជទូតថៃមានប្រសាសន៍ថា: ដង្វាយនេះកើតឡើងដោយក្តីសប្បុរសរបស់ ឯ.ឧ និងមន្ត្រីស្ថានទូតថៃប្រចាំនៅកម្ពុជា ដើម្បីចូលរួមដង្ហែតាមព្រះរាជសកម្មភាពមនុស្សធម៌ ដ៏ថ្លៃថ្លារបស់ព្រះករុណាជាអម្ចាស់ ដើម្បីព្រះអង្គមានលទ្ធភាពក្នុងការបន្តជួយសង្គ្រោះដល់ប្រជារាស្ត្រកម្ពុជា ដែលជួបការលំបាកឱ្យទទួលបានភាពល្អប្រសើរឡើងវិញ ។

ព្រះមហាក្សត្រកម្ពុជាបានស្វាគមន៍ថ្លែងអំណរគុណដល់ ឯ.ឧ ឯកអគ្គរាជទូតថៃដែលបានចូលគាល់ និងបាននាំមកនូវជំនួយដ៏វិសេសវិសាល ថ្វាយព្រះអង្គនាឱកាសនោះ ហើយព្រះអង្គនឹងប្រោសប្រទានជាប្រយោជន៍ក្នុងការជួយសំរាលការលំបាកក្នុងជីវភាពរបស់ប្រជារាស្ត្រ នៅតាមមូលដ្ឋានជនបទនានា ដែលបងប្អូនត្រូវការជាចាំបាច់នូវជំនួយដ៏ថ្លៃថ្លាពីសប្បុរសជន ។

ព្រះមហាក្សត្រកម្ពុជាបានថ្លែងអំណរគុណផងដែរចំពោះរាជរដ្ឋាភិបាលថៃ ដែលបានផ្តល់ជំនួយគាំទ្រដល់ដំណើរការអភិវឌ្ឍន៍នៅកម្ពុជា ។ ព្រះករុណាក៏បានកោតសរសើរដល់ឯកអគ្គរាជទូតថៃដែលបានខិតខំបំពេញបេសកកម្មការទូតដ៏ថ្លៃថ្លា ធ្វើឱ្យទំនាក់ទំនងចំណងសាមគ្គីភាព រវាងប្រទេសយើងទាំងពីរ (កម្ពុជា-ថៃ) មានភាពរឹងមាំរីកចំរើនឡើងជាលំដាប់ ។

តាមរយៈឯកអគ្គរាជទូតថៃ ព្រះមហាក្សត្រកម្ពុជាបានផ្តាំផ្ញើព្រះរាជបណ្តាំសាកសួរសុខទុក្ខ ចំពោះព្រះករុណាព្រះមហាក្សត្រថៃ និងព្រះរាជអគ្គមហេសី សូមព្រះអង្គមានព្រះរាជសុខភាពល្អបរិបូរណ៍ ព្រះជន្មវស្សាយឺនយូរ និងបានប្រោសប្រទានពរជ័យជូនរាជរដ្ឋាភិបាលថៃ និងជូនពរ ឯ.ឧ ឯកអគ្គរាជទូតថៃ និងមន្ត្រីស្ថានទូតថៃផងដែរ ។/

## ព្រះមហាក្សត្រប្រោសព្រះរាជទានឱ្យ ឯកឧត្តម សុខ ស៊ីផាន់ណា និងក្រុមគ្រួសារចូលបង្គំគាល់

*លោក ចង លីមអ៊ី AKP ភ្នំពេញ*

នៅប្រាសាទខេមរិន្ទក្នុងព្រះបរមរាជវាំងថ្ងៃទី៩ កញ្ញា ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ព្រះអង្គបានសព្វព្រះរាជហឫទ័យប្រោសព្រះរាជទានដល់ ឯកឧត្តម សុខ ស៊ីផាន់ណា និងក្រុមគ្រួសារ បានចូលក្រាបថ្វាយបង្គំគាល់ក្នុងឱកាសដែលឯកឧត្តមបណ្ឌិតនឹងត្រូវអញ្ជើញទៅបំពេញភារកិច្ចនៅឯបរទេស ។

ឯកឧត្តម សុខ ស៊ីផាន់ណា បានទូលថ្វាយឱ្យដឹងថា កាលពីដើមខែសីហា កន្លងមកនេះ ឯកឧត្តមផ្ទាល់ ត្រូវបានជ្រើសរើសឱ្យធ្វើជានាយផ្នែកសំរបសំរួលសហប្រតិបត្តិការបច្ចេកទេសរបស់មជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ "ITC" ដែលជាភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់សន្និសីទអង្គការសហប្រជាជាតិដើម្បីពាណិជ្ជកម្ម និងការអភិវឌ្ឍន៍ និងអង្គការពាណិជ្ជកម្មពិភពលោក "WTO" មានទីស្នាក់ការកណ្តាលនៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ។ ឯកឧត្តមត្រូវបានជ្រើសក្នុងចំណោមបេក្ខជនជាង ១០០ នាក់ នៅទូទាំងពិភពលោក ហើយនឹងត្រូវទៅបំពេញភារកិច្ចថ្មីនេះនៅពាក់កណ្តាលខែកញ្ញា ឆ្នាំ២០០៩ ។

ព្រះករុណា ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ព្រះអង្គបានសព្វព្រះរាជហឫទ័យចូលរួមសំដែងការអបអរចំពោះតំណែងថ្មីដ៏ឧត្តុង្គឧត្តមនេះ ហើយព្រះអង្គទ្រង់ព្រះរាជទានពរជ័យដល់ឯកឧត្តមបណ្ឌិតសំរេចបានមហាជោគជ័យក្នុងការបំពេញភារកិច្ចដ៏មានខ្លឹមសារនេះ ដើម្បីនាំមកនូវឧត្តមប្រយោជន៍ដល់ព្រះរាជាណាចក្រកម្ពុជាយើងឱ្យកាន់តែប្រសើរឡើងថែមទៀត ។/

# សម្តេច ហ៊ុន សែន ទទួលមេដាយសន្តិភាព U Thant

*លោក ជ័យ ភូមិពល AKP ភ្នំពេញ*

សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវបានប្រគល់មេដៃសន្តិភាព U Thant កាលពីម្សិលមិញដោយមជ្ឈមណ្ឌលស្រ៊ីជិនម៉យអន្តរជាតិ ដែលជាមេដាយលំដាប់ពិភពលោកខ្ពស់បំផុតសម្រាប់ឥស្សរជន និងអង្គការនានាដែលល្បីឈ្មោះបំផុត ចំពោះការបរិច្ចាគដើម្បីសន្តិភាព និងភាពរុងរឿងរបស់មនុស្សជាតិ ។

លោក ស្រ៊ី ជិនម៉យ ប្រធានមជ្ឈមណ្ឌល ស្រ៊ី ជិនម៉យ អន្តរជាតិ បានបំពាក់មេដាយនេះ ជូនសម្តេច ហ៊ុន សែន ដែលជាមេដៃសន្តិភាពកិត្តិយពិភពលោកទី២ ដែលត្រូវបានបំពាក់ដោយលោក ស្រ៊ី ជិនម៉យ ចាប់តាំងពីឆ្នាំ២០០១មក ។

នៅឯទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាកន្លែងដែលប្រាព្ធពិធីនោះ ក្រុមគ្រួសារ រួមទាំងមហាឧបាសិកា ហ៊ុន នាង ដែលជាបិតារបស់លោក និងឥស្សរជនជាន់ខ្ពស់ជាតិ-អន្តរជាតិ បានចូលរួមអបអរសាទរក្នុងពិធីដ៏មហោឡារិក និងដោយមហាកិត្តិយសនេះ ។

សេចក្តីថ្លែងការណ៍របស់មជ្ឈមណ្ឌលអន្តរជាតិ ស្រ៊ី ជិនម៉យ រង្វាន់សន្តិភាព U Thant និយាយថា រង្វាន់ដែលលោក ស្រ៊ី ជិនម៉យ ផ្តល់ជូនជាតំណាងឱ្យការធ្វើភាវនាសន្តិភាពនៅអង្គការសហប្រជាជាតិនេះបានឱ្យឈ្មោះរបស់លោកអតីតអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។ រង្វាន់នេះធ្វើឱ្យមានការចងចាំជារៀងរហូតនូវអនុស្សាវរីយ៍នៃលោក អ៊ូ ថាន់ និងសេចក្តីស្រឡាញ់ដ៏ជ្រាលជ្រៅជាគំរូចំពោះសន្តិភាពរបស់លោកទាំងក្នុងជីវិតនយោបាយ និងជីវិតផ្ទាល់ខ្លួន ។

ចាប់តាំងពីត្រូវបានបង្កើតមក មានឥស្សរជនចំនួន ៥នាក់ហើយ ដែលបានទទួលមេដាយសន្តិភាព U Thant នេះ ដែលរួមមាន: លោកប្រធានាធិបតីសហភាពសូវៀត មីខាអ៊ែរ ហ្គោបាឆិវ ប្រធានាធិបតីអាហ្វ្រិកខាងត្បូង នេលសាន់ ម៉ានដេឡា សម្តេច ប៉ាប ចនប៉ូលទី២ អ្នកម្តាយ តេ រេសា និងសង្ឃនាយក ដេសម៉ុនដ៍ ទូទូ នៃអាហ្វ្រិកខាងត្បូង ។

សម្តេច ហ៊ុន សែន ដែលបានចំណាយពេលវេលាស្ទើរតែមួយជីវិតរបស់លោកក្នុងការស្វែងរកសន្តិភាព ហើយនៅទីបំផុត លោកបានធ្វើឱ្យទឹកដីកម្ពុជាទាំងមូលបានទទួលសន្តិភាពទាំងស្រុង គ្មានតំបន់អបគមន៍នៅឆ្នាំ១៩៩៩ ក្រោមនយោបាយឈ្នះ២ ។ លោកគឺជាឥស្សរជនទី៦ ដែលទទួលបានមេដាយដ៏ខ្ពង់ខ្ពស់នេះ ។

សម្តេច ហ៊ុន សែន មានប្រសាសន៍ " ខ្ញុំសូមសំដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ជូនចំពោះមជ្ឈមណ្ឌលអន្តរជាតិ ស្រ៊ី ជិនម៉យ ចំពោះមហាកិត្តិយសដែលមជ្ឈមណ្ឌលបានបំពាក់មេដាយសន្តិ

ភាព U Thant ដល់ខ្ញុំ ហើយប្រការនេះ គឺជាមហាកិត្តិយសរបស់ខ្ញុំផ្ទាល់ ក៏ដូចជារបស់កម្ពុជាទាំងមូលផងដែរ ” ។ សម្តេចថ្លែងថា កិត្តិយសដ៏គួរឱ្យមោទនៈនេះ គឺពិតជាបានឆ្លុះបញ្ចាំងពីកិច្ចប្រឹងប្រែងរបស់ប្រជាជាតិយើងកន្លងមក ក៏ដូចជាកិច្ចការ និងការលះបង់បន្តទៀត ដើម្បីបុព្វហេតុនៃការពង្រឹងសន្តិភាព ស្ថិរភាព លទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ព្រមទាំងការអភិវឌ្ឍន៍ប្រកបដោយចិរភាព និងសមធម៌នៅកម្ពុជា ។

សម្តេច ហ៊ុន សែន មានប្រសាសន៍ថា បច្ចុប្បន្នយើងបាននឹងកំពុងបោះជំហានទៅមុខ ដោយខិតខំធ្វើកំណែទម្រង់ឱ្យបានគ្រប់ជ្រុងជ្រោយ និងស៊ីជំរៅនៅគ្រប់មុំទាំងអស់នៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។ សម្តេចថ្លែងថា “ខ្ញុំពិតជាមានមោទនភាពចំពោះសមិទ្ធផលសំខាន់ៗជាច្រើនដែលយើងសំរេចបាននន្លងមកនេះ ប៉ុន្តែទោះបីយ៉ាងណា ខ្ញុំសូមបញ្ជាក់ថា យើងនៅមានកិច្ចការជាច្រើនទៀតដែលត្រូវធ្វើនៅលើមាគ៌ាដែលយើងបានត្រួសត្រាយមកហើយនេះ” ។/

## សម្តេចអនុប្រធានទី១ ព្រឹទ្ធសភា ទទួលជួបគណៈប្រតិភូជប៉ុន

*លោក ជីម ណារី AKP ភ្នំពេញ*

សម្តេច ស៊ីសុវត្ថិ ជីវ័នមុនីរក្ស អនុប្រធានទី១ ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យគណៈប្រតិភូប្រទេសជប៉ុន ដឹកនាំដោយលោក TAKUJI OKUNO បណ្ឌិតសាស្ត្រាចារ្យសង្គមវិទ្យានៃសាកលវិទ្យាល័យ KWAN SEIGAKUIM ចូលជួបសំដែងការគួរសមនាព្រឹកថ្ងៃទី៦ កញ្ញា ឆ្នាំ ២០០៥ នៅអគ្គលេខាធិការដ្ឋាន ។

លោក TAKUJI OKUNO បានជំរាបជូនសម្តេចអនុប្រធានទី១ ព្រឹទ្ធសភា ថា សំណើរទស្សនកិច្ចរបស់គណៈប្រតិភូជប៉ុនមកកាន់ប្រទេសកម្ពុជា គឺដើម្បីស្វែងយល់អំពីសភាពការណ៍នៅក្នុងប្រទេសកម្ពុជា ព្រមទាំងពិនិត្យមើលអំពីសេចក្តីត្រូវការរបស់កម្ពុជា សំរាប់ការបណ្តុះបណ្តាលធនធានមនុស្សតាមរយៈមូលនិធិរបស់ក្រុមហ៊ុន NISSAN ។ លោកបានបន្តថា : តាមរយៈមូលនិធិរបស់ក្រុមហ៊ុន NISSAN នេះ លោកនឹងខិតខំជួយដល់ការបណ្តុះបណ្តាលធនធានមនុស្សឱ្យទទួលបានជោគជ័យ ។

សម្តេច ជីវ័ន មុនីរក្ស អនុប្រធានទី១ ព្រឹទ្ធសភា បានសំដែងនូវការស្វាគមន៍ចំពោះបំណងដ៏ល្អរបស់គណៈប្រតិភូជប៉ុនក្នុងការជួយបណ្តុះបណ្តាលធនធានមនុស្សនៅក្នុងប្រទេសកម្ពុជា ។ សម្តេចក៏បានសំដែងនូវក្តីសង្ឃឹមថា: តាមរយៈមូលនិធិរបស់ក្រុមហ៊ុន NISSAN ដែលនឹងចាប់ផ្តើមនៅឆ្នាំ២០០៦ នោះនឹងជួយជំរុញការបណ្តុះបណ្តាលធនធានមនុស្សក្នុងប្រទេសកម្ពុជា ក៏ដូចជាអាស៊ាននឹងទទួលជោគជ័យជាក់ជាពុំខាន ។/

# សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន នឹងដឹកនាំគណៈប្រតិភូជាន់ខ្ពស់ ចូលរួមប្រជុំមហាសន្និបាត អ.ស.ប លើកទី៦០

*AKP ភ្នំពេញ*

តាមសេចក្តីប្រកាសព័ត៌មានរបស់នាយកដ្ឋានព័ត៌មាន និងឯកសារនៃក្រសួងការបរទេស ចេញផ្សាយថ្ងៃទី០៩ កញ្ញា ២០០៥ មានខ្លឹមសារថា ៖

សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នឹងដឹកនាំគណៈប្រតិភូជាន់ខ្ពស់ចូលរួមកិច្ចប្រជុំពេញអង្គថ្នាក់ខ្ពស់នៃមហាសន្និបាតអង្គការសហប្រជាជាតិលើកទី ៦០ ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៦ កញ្ញា ឆ្នាំ២០០៥ នៅបូរីញូវយ៉ក ។

ក្រៅពីកិច្ចប្រជុំពេញអង្គថ្នាក់ខ្ពស់នៃមហាសន្និបាតអង្គការសហប្រជាជាតិលើកទី៦០ សម្តេចនាយករដ្ឋមន្ត្រី នឹងចូលរួមក្នុងកិច្ចប្រជុំកំពូលអាស៊ាន-អង្គការសហប្រជាជាតិលើកទី២ និងកិច្ចប្រជុំកំពូលថ្នាក់ដឹកនាំបណ្តាប្រទេសនិយាយភាសាបារាំង ។

គណៈប្រតិភូរួមមានឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងមន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាលកម្ពុជាជាច្រើនរូបទៀត ។

សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន នឹងថ្លែងសុន្ទរកថា ទៅកាន់កិច្ចប្រជុំពេញអង្គថ្នាក់ខ្ពស់នៃមហាសន្និបាតអង្គការសហប្រជាជាតិលើកទី៦០ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៥ ។

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង នឹងចូលរួមកិច្ចប្រជុំក្រៅផ្លូវការរដ្ឋមន្ត្រីការបរទេសអាស៊ាន នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៥ នៅបូរីញូយ៉ក ហើយរួមជាមួយរដ្ឋមន្ត្រីការបរទេសអាស៊ាន ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី នឹងជួបលោកជំទាវ កុងដូលីហ្សា រ៉ៃ (Condoleezza Rice) រដ្ឋមន្ត្រីការបរទេស សហរដ្ឋអាមេរិក ។

បន្ទាប់ពីកិច្ចប្រជុំទាំងនេះ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន នឹងអញ្ជើញទៅបំពេញទស្សនកិច្ចការងារនៅសាធារណរដ្ឋបារាំង ចាប់ពីថ្ងៃទី១៩ ដល់ ២០ ខែកញ្ញា ឆ្នាំ២០០៥ ។/

# ធនាគារពិភពលោកស្វែងយល់អំពីការអនុវត្តន៍យុទ្ធសាស្ត្រទ្រទ្រង់ជំនួយនៅកម្ពុជា

*លោក អ៊ុក សាផាន AKP ភ្នំពេញ*

គណៈប្រតិភូធនាគារពិភពលោក ដឹកនាំដោយ លោក IAN PORTER នាយកធនាគារពិភពលោក (WB) ប្រចាំប្រទេសកម្ពុជា ឡាវ ម៉ាឡេស៊ី និងថៃ បានជួបពិភាក្សាការងារជាមួយ ឯ.ឧ ឧប

នាយករដ្ឋមន្ត្រី សុខ អាន រដ្ឋមន្ត្រីទីស្ដីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលសាធារណៈ នាទីស្ដីការគណៈរដ្ឋមន្ត្រី នាព្រឹកថ្ងៃទី០៦ កញ្ញា ២០០៥ ។

ឯកឧត្តម ង៉ោ ហុងលី អគ្គលេខាធិការក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល បានប្រាប់អ្នកសារពត៌មានក្រោយពីបញ្ចប់ជំនួបនេះថា : គោលបំណងនៃជំនួបនេះ គឺដើម្បីផ្លាស់ប្ដូរយោបល់ និងសុំការណែនាំខ្លះពី ឯ.ឧ សុខ អាន អំពីការអនុវត្តន៍នូវយុទ្ធសាស្ត្រទ្រទ្រង់ដល់ជំនួយកម្ពុជារបស់ WB ។ នៅក្នុងជំនួបនេះលោក IAN PORTER និងប្រតិភូក៏បានកោតសរសើរពីការរីកចំរើនរបស់កម្ពុជាលើគ្រប់វិស័យ តាំងពីកិច្ចប្រជុំពិគ្រោះយោបល់ខែធ្នូ ២០០៤ មក ។ ក្នុងនោះ លោកបានលើកអំពីផ្នែកសេដ្ឋកិច្ចមានការរីកចំរើនក៏ដូចជាការកែទំរង់នានា ពិសេសកំណែទំរង់រដ្ឋបាលសាធារណៈ ។

ទាក់ទិនកិច្ចសហប្រតិបត្តិការរវាង WB ជាមួយកម្ពុជាក្នុងការជួយកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍ប្រទេសជាតិ លោក IAN PORTER មានប្រសាសន៍ថា ប្រទេសផ្ដល់ជំនួយត្រូវការកែទម្រង់របស់ខ្លួនដែរ ត្រូវរកផ្លូវផ្សេងដែលកន្លងមកគាត់ធ្វើការជាមួយកម្ពុជា ដោយត្រូវកែសំរួលឡើងវិញនូវរបៀបរបបធ្វើការ ធ្វើយ៉ាងណាសំដៅពង្រីកគុណភាពនៃជំនួយរបស់គាត់ដល់កម្ពុជា និងពង្រឹងភាពជាដៃគូជាមួយកម្ពុជា ។

ក្នុងឱកាសនេះដែរ លោក IAN PORTER ក៏បានលើកប្រធានបទ ៤ ជូន ឯ.ឧ ឧបនាយករដ្ឋមន្ត្រី ដើម្បីសុំយោបល់ គឺប្រធានបទពាក់ព័ន្ធការកែទំរង់សាធារណៈ កំណែទំរងរដ្ឋបាលសាធារណៈ ការអភិវឌ្ឍន៍ផ្នែកឯកជន ការគ្រប់គ្រងធនធានធម្មជាតិ និងប្រធានបទពាក់ព័ន្ធនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា ។

ឆ្លើយតបទៅនឹងការលើកឡើងខាងលើនោះ ឯ.ឧ ឧបនាយករដ្ឋមន្ត្រី បានស្វាគមន៍ចំពោះការវាយតំលៃរបស់ WB លើការរីកចំរើនរបស់កម្ពុជា ពិសេសកំណែទំរង់រដ្ឋបាលសាធារណៈ ដោយ ឯ.ឧ ជំរាបជូនអំពីដំណើរការនៃកំណែទំរង់រដ្ឋបាលសាធារណៈ ដែលបានរៀបចំយុទ្ធសាស្ត្រច្បាស់លាស់ ស្របតាមសភាពការណ៍ជាក់ស្ដែងនៅកម្ពុជា ហើយ ឯ.ឧ បានឧទ្ទេសនាមយ៉ាងក្បោះក្បាយនៅក្នុងសិក្ខាសាលាជាតិស្ដីពីការរៀបចំផែនការមេសំរាប់ពង្រឹងធនធានមនុស្សនៅកម្ពុជា ។

ឯកឧត្តម សុខ អាន ក៏បានរំលឹកយុទ្ធសាស្ត្រទាំង ៥ គឺការកែលំអការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ការបង្កើនបៀវត្ស និងការពង្រឹងការគ្រប់គ្រងនិយោជនៅក្នុងរដ្ឋបាលសាធារណៈ ការអភិវឌ្ឍន៍សមត្ថភាពមន្ត្រីរាជការ ការជំរុញឱ្យប្រើប្រាស់នូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ICT ក្នុងរដ្ឋបាលសាធារណៈ និងចំណុចស្នូលការប្រើប្រាស់ឱ្យអនុវត្តកន្សោមអាទិភាព ការកែទំរង់ហិរញ្ញវត្ថុសាធារណៈជាផ្នែកមួយនៃការកែទំរង់រដ្ឋ ។

ចំពោះវិស័យកំណែទំរង់នេះ ឯ.ឧ សុខ អាន បានធ្វើការប្រៀបធៀបកម្ពុជាទៅនឹងកប៉ាល់មួយ

លើមហាសាគរ ប្រសិនបើមានបញ្ហាអស្ថេរភាពខាងក្នុងជម្លោះផ្ទៃក្នុងកប៉ាល់នឹងលិច ហើយប្រសិនបើយើងមិនធ្វើការកែទំរង់ទេ កប៉ាល់យើងក៏ត្រូវច្រេះចាប់ ហើយក៏ធ្លាយលិចក្នុងទឹកដូចគ្នា ។ មានន័យថា យើងធ្វើការកែទំរង់ដោយមានការប្រុងប្រយ័ត្នបំផុត ។ ដោយឡែកបញ្ហាបៀវត្ស អ្វីដែលសំខាន់ គឺយើងត្រូវឡើងបៀវត្សដោយមានលក្ខណៈចេរភាព ពីព្រោះតែឡើងហើយមិនអាចថយវិញបានទេ ។ ហេតុនេះបញ្ហាប្រឈមដ៏ធំនោះ គឺការរកចំណូល ។

ពាក់ព័ន្ធការគ្រប់គ្រងធនធានធម្មជាតិ ឯ.ឧ សុខ អាន បានគូសបញ្ជាក់ពីការខិតខំរបស់រដ្ឋាភិបាលក្នុងការរៀបចំលិខិតបទដ្ឋានបំពេញ-សម្រួលក្នុងការគ្រប់គ្រងដីធ្លី ព្រៃឈើ ។ រាជរដ្ឋាភិបាលក៏បានរៀបចំលិខិតបទដ្ឋានមួយចំនួនដើម្បីជំរុញវិស័យសហគ្រាសធុនតូច-មធ្យម ។ ចំពោះវិមជ្ឈការ និងវិសហមជ្ឈការ ឯ.ឧ ក៏បានគូសបញ្ជាក់ពីគោលជំហររបស់រាជរដ្ឋាភិបាលចំពោះការងារនេះ និងអំពីសារៈសំខាន់នៃគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការដែលធ្វើដោយមានការប្រុងប្រយ័ត្នឆ្លើយតបទៅនឹងសភាពការណ៍ជាក់ស្តែងរបស់សង្គម ។

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ក៏បានអបអរសាទរចំពោះការទទួលលិខិតមួយពី WB ដែលបានទទួលស្គាល់នូវការរីកចំរើនរបស់កម្ពុជាក្នុងការងារកែទំរង់រដ្ឋបាលសាធារណៈ ។ ខ្លឹមសារនៃលិខិតនោះក៏បានចែងថា: កន្លងមកយើងមានទស្សនៈខុសគ្នាខ្លះដែលធ្វើអោយការជជែកកិច្ចសហប្រតិបត្តិការមានសភាពតឹងតែងនៅពេលខ្លះ ប៉ុន្តែជាងកន្លះឆ្នាំនេះ WB បានទទួលស្គាល់នូវការវាយតំលៃខុសគ្នារវាងភាគីកម្ពុជា និង WB ដែលជាចំណុចមួយជំរុញអោយមានការរីកចំរើននៃកិច្ចសហប្រតិបត្តិការរវាងភាគីកម្ពុជា និង WB ។/

## នាវាហ្វឹកហ្វឺនជប៉ុនចំនួន ០៣គ្រឿង ចូលចតកំពង់ផែសមុទ្រ ក្រុងព្រះសីហនុ

*លោក ង៉ូ សុមុនី AKP ក្រុងព្រះសីហនុ*

ព្រឹកថ្ងៃទី០៦ ខែកញ្ញា ២០០៩នេះ នាវាហ្វឹកហ្វឺនកងស្វ័យត្រាណជើងទឹកជប៉ុនចំនួន ០៣គ្រឿងបានចូលចតនៅកំពង់ផែសមុទ្រ ក្រុងព្រះសីហនុ រយៈពេល ៤ថ្ងៃ ដើម្បីធ្វើទស្សនកិច្ចសុឆន្ទៈ និងការអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំជំនាញគ្រប់គ្រង និងធ្វើទំនាក់ទំនងល្អជាមួយព្រះរាជាណាចក្រកម្ពុជា ដោយមានការទទួលស្វាគមន៍ពីសំណាក់កងទ័ពជើងទឹកតំបន់សមុទ្ររាម ។

ក្នុងជំនួបជាមួយអ្នកសារព័ត៌មាន លោកឧត្តមនាវីទោ ម៉ាសាហ៊ីរ៉ូ ស៊ីតាតា មេបញ្ជាការនាវាហ្វឹកហ្វឺននៃកងស្វ័យត្រាណជប៉ុនបានមានប្រសាសន៍ឱ្យដឹងថា: នាវាទាំង ៣គ្រឿងនេះ មានឈ្មោះ KAS-HIMA មានបណ្តោយ ១៤៣ម៉ែត្រ ទទឹង ១៨ម៉ែត្រ ជំរៅ ១២,៣ម៉ែត្រ មានទម្ងន់ ៤០៥០តោន

មាននាវិក ៣៦០នាក់ នាវាទី២ មានឈ្មោះ MURASAME មានបណ្តោយ ១៥១ម៉ែត្រ ទទឹង ១៧,៤ម៉ែត្រ ជំរៅ ១០,៩ម៉ែត្រ មានទម្ងន់ ៤.៥៥០តោន មាននាវិក ១៦៥នាក់ នាវាទី៣ ឈ្មោះ YU-GIRI បណ្តោយ ១៣៧ម៉ែត្រ ទទឹង ១៤,៦ម៉ែត្រ ជំរៅ ៨,៨ម៉ែត្រ ទម្ងន់ ៣៥០០តោន ដែលមាននាវិក ២២០នាក់ សរុបទាំងអស់មានចំនួន ៧៤៥នាក់ ។ នាវាទាំង ០៣គ្រឿងនេះ បំពាក់ទៅដោយសព្វាវុធទំនើបៗ ដូចជាកាំភ្លើងយន្ត ៧៦,៦២ម.ម កាណុងគ្រាប់បែកបាញ់នាវា ៣២៤ម.ម មីស៊ីលបាញ់ពីដីទៅអាកាស និងឧទ្ទម្ភាចក្រប្រឆាំងនាវាមុជទឹក ។

លោកមេបញ្ជាការបានបញ្ជាក់ទៀតថា នាវានេះបានចេញដំណើរពីប្រទេសជប៉ុន ដើម្បីធ្វើការហ្វឹកហ្វឺនជារៀងរាល់ឆ្នាំ ដើម្បីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំជំនាញគ្រប់គ្រង និងបើកបរនាវារបស់នាយនាវិកជំនាន់ថ្មីតាមរយៈការហ្វឹកហាត់លើសមុទ្រ ហើយក៏ជាការពង្រឹង និងពង្រីកទស្សនវិស័យជាលក្ខណៈអន្តរជាតិជាមួយប្រទេសផ្សេងៗ ។ នាវានេះចាកចេញពីប្រទេសជប៉ុន កាលពីថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៥ និងធ្វើទស្សនកិច្ចជុំវិញពិភពលោកនៅបណ្តាប្រទេសចំនួន ១៥ ។ ហើយការស្នាក់នៅរយៈពេល ០៤ថៃខាងមុខនេះ គឺជាប្រវត្តិសាស្ត្រសំរាប់ទំនាក់ទំនងសហប្រតិបត្តិការរវាងប្រទេសទាំងពីរជប៉ុន-កម្ពុជា។ នាវាទាំង ០៣គ្រឿងនេះ ០២គ្រឿងជានាវាប្រើប្រាស់ ដើម្បីការពារក្នុងការធ្វើដំណើរចេញទៅក្រៅប្រទេស ហើយនាវាស្វ័យត្រាណធ្លាប់បានចូលរួមក្នុងសកម្មភាពរបស់អ៊ុនតាក់ (UNTAC)កាលពីឆ្នាំ១៩៩២-១៩៩៣ នៅកម្ពុជា ។

គណៈប្រតិភូមានគំរោងទៅធ្វើទស្សនកិច្ចនៅមូលដ្ឋានកងទ័ពជើងទឹកតំបន់សមុទ្ររាម និងទៅធ្វើទស្សនកិច្ចនៅភ្នំពេញ ដាក់កម្រងផ្កានៅវិមានឯករាជ្យ ទស្សនារមណីយដ្ឋានវត្តភ្នំ ជួបសំដែងការគួរសមជាមួយរដ្ឋមន្ត្រីក្រសួងការពារជាតិ និងចូលជួបសំដែងការគួរសមជាមួយព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ហើយនៅថ្ងៃទី០៩ កញ្ញា ២០០៥ នាវាហ្វឹកហ្វឺនជប៉ុនទាំង ០៣គ្រឿងនេះ នឹងចាកចេញពីកំពង់ផែក្រុងព្រះសីហនុ ។

កាលពីចុងខែសីហា ឆ្នាំ២០០៥ កន្លងមកនេះ ក៏មាននាវាចំបាំងប្រទេសអូស្ត្រាលី ០១គ្រឿង ដែលមានប្រវែង ១៣៩ម៉ែត្រ និងមាននាវិក ២០៥នាក់ បានចូលចតកំពង់ផែសមុទ្រ ក្រុងព្រះសីហនុ ដើម្បីធ្វើទស្សនកិច្ចរយៈពេល ០៥ថ្ងៃ នៅក្នុងព្រះរាជាណាចក្រកម្ពុជាដែរ ។/

## បើកការដ្ឋានសាងសង់ផ្លូវក្រាលគ្រួសក្រហមក្នុងឃុំឱម៉ាល់ និងឃុំជ្រៃ

*លោក ឡេង ហុក AKP បាត់ដំបង*

ផ្លូវក្រាលគ្រួសក្រហមប្រវែង ៦.៤០០ម៉ែត្រ ស្ថិតក្នុងឃុំឱម៉ាល់ ស្រុកបាត់ដំបង និងឃុំជ្រៃ ស្រុក

ថ្មគោល ចាប់ពីចំណុចផ្លូវជាតិលេខ៥៧ មកទល់ផ្លូវជាតិលេខ៥ ត្រូវបានបើកការដ្ឋានសាងសង់ ក្រោមអធិបតីភាព ឯកឧត្តម ប្រាជ្ញ ចន្ទ អភិបាលខេត្តបាត់ដំបង និងអភិបាលរងខេត្ត កាលពីព្រឹកថ្ងៃទី៦ កញ្ញា ឆ្នាំ២០០៥ ។

លោក អែល សយ ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តបាត់ដំបង បានរាយការណ៍ឱ្យដឹងថា: ផ្លូវក្រាលគ្រួសក្រហមនេះ មានប្រវែង ៦.៤០០ម៉ែត្រ ទទឹង ៥ម៉ែត្រ ការជួសជុសដោយថវិការបស់ក្រសួងអភិវឌ្ឍន៍ជនបទ ។ ផ្លូវនេះដំណើរការលើឃុំពីរ គឺឃុំជ្រៃ ស្រុកថ្មគោល និងឃុំឱម៉ាល់ ស្រុកបាត់ដំបង សម្រាប់បំរើប្រជាពលរដ្ឋចំនួន ៤.៨១៧គ្រួសារ និងធ្វើការអនុវត្តន៍ឱ្យបានចប់រួចរាល់ក្នុងមួយសប្តាហ៍ខាងមុខនេះ ។

ឯកឧត្តម ប្រាជ្ញ ចន្ទ មានប្រសាសន៍ថា: ផ្លូវនេះជាខ្សែក្រវាត់ក្រុងបាត់ដំបងទី២ ផ្លូវនេះមានយូរមកហើយ តែខូចខាតពិបាកធ្វើចរាចរណាស់ ។ ទើបពេលនេះក្រសួងអភិវឌ្ឍន៍ជនបទសំរេចកំរោងសាងសង់ធ្វើផ្លូវក្រាលគ្រួសក្រហមកម្រាស់ ២តឹក និងឈានទៅការចាក់កៅស៊ូនៅពេលក្រោយ ។

ឯកឧត្តម បានសំណូមពរដល់ប្រជាពលរដ្ឋទាំងពីរឃុំនេះ មេត្តាធ្វើយ៉ាងណាជួយថែរក្សាផ្លូវនេះឱ្យបានយូរអង្វែងជួយការពារកុំឱ្យមានទឹកដក់តាមដងផ្លូវ និងធ្វើយ៉ាងណាហាមឃាត់កុំឱ្យរថយន្តធំៗដឹកទំនិញលើសទម្ងន់បើកបរឆ្លងកាត់នៅពេលមានដីសើម ។

ទាក់ទិនទៅនឹងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ឯកឧត្តម មានប្រសាសន៍ថា : កាលពីដើមរដូវមានភ្លៀងធ្លាក់បង្គួរ ធ្វើឱ្យការសាបព្រោះស្រូវ និងភ្ជួររាស់បានល្អបង្គួរ តែមកដល់សព្វថ្ងៃនេះ មានការរាំងស្ងួតនៅស្ទើរគ្រប់ស្រុករបស់ខេត្តបាត់ដំបង ធ្វើឱ្យដំណាំស្រូវយ៉ាងច្រើនហិកតាមានការខ្វះខាតទឹក ។

ឯកឧត្តម បានសំណូមពរដល់ប្រជាពលរដ្ឋទាំងអស់ ក្រៅពីការធ្វើស្រែត្រូវតែខិតខំដាំដំណាំរួមផ្សំជាច្រើនប្រភេទទៀត ដើម្បីជាជំនួយក្នុងការដោះស្រាយជីវភាពរបស់បងប្អូនប្រជាពលរដ្ឋផងដែរ ។/

## ស្រុកសំឡូតដាំកូនឈើចំនួន ២.០០០ដើម

*លោក ឡេង ហុក AKP បាត់ដំបង*

កូនឈើចំនួន ២.០០០ដើម ត្រូវបានធ្វើពិធីដាំលើខ្នងភ្នំក្នុងភូមិព្រៃរំចេក ឃុំតាសាញ ស្រុកសំឡូត ក្រោមអធិបតីភាព ឯ.ឧ ប្រាជ្ញ ចន្ទ អភិបាលខេត្តបាត់ដំបង និងលោក សួរ សាម៉េត បញ្ជាការរងយោធភូមិភាគ៥ ប្រចាំទិសសំឡូត កាលពីព្រឹកថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៥ ។

លោក ហែន សុផល អភិបាលស្រុកសំឡូត បានឱ្យដឹងថា : ស្រុកសំឡូតមានប្រជាពលរដ្ឋរស់នៅចំនួន ៦.១៥១គ្រួសារ ចែកចេញជា ៧ឃុំ ៤៩ភូមិ ហើយមានតំបន់ការពារបរិស្ថាន ប្រមាណជិត

៤០.០០០ហិកតា ។

កូនឈើទាំង ២.០០០ដើមនេះ បានមកពីការឧបត្ថម្ភរបស់អង្គភាពរដ្ឋបាលព្រៃឈើ ក្នុងនោះមានប្រភេទបេង គគី និងអាកាស្យា ។ ការដាំកូនឈើនេះក្នុងបំណងស្តារ និងកែប្រែភ្នំទាំងនេះឱ្យមានលក្ខណៈជាព្រៃភ្នំឡើងវិញ និងសូមឱ្យប្រជាពលរដ្ឋដែលមានការពាក់ព័ន្ធស្ម័គ្រចិត្តប្រគល់ដីភ្នំទាំងនេះមកឱ្យរដ្ឋវិញ ព្រោះដីភ្នំ តាមរដ្ឋធម្មនុញ្ញ ជាសម្បត្តិរបស់រដ្ឋ ។

ឯកឧត្តម ប្រាជ្ញ ចន្ទ អភិបាលខេត្តបាត់ដំបង មានប្រសាសន៍ក្នុងពិធីនោះថា ៖ ដើមឡើយស្រុកសំឡូត គឺជាស្រុកមួយមានឈ្មោះថា ជាស្រុកសំបូរទៅដោយសម្បត្តិធម្មជាតិ ទាំងព្រៃភ្នំ ទឹកជ្រោះ សត្វក៏ដូចជារ៉ែធម្មជាតិ ហើយដីក៏មានជីវជាតិល្អទៀតផង ។ ហើយតំបន់មួយចំនួនរបស់ស្រុកសំឡូត ដូចជាតំបន់ព្រៃសំកុសជាកន្លែងធនធានធម្មជាតិចំរុះ ជាកន្លែងថែរក្សាសត្វព្រៃ និងមានព្រំប្រទល់ជាប់ខេត្តពោធិសាត់ បាត់ដំបង និងខេត្តកោះកុង ។

ឯកឧត្តម ប្រាជ្ញ ចន្ទ បន្តទៀតថា៖ បច្ចុប្បន្នរាជរដ្ឋាភិបាលផ្អែកតាមច្បាប់ស្តីពីការគ្រប់គ្រងព្រៃឈើ និងច្បាប់បរិស្ថាន ហើយថ្មីៗនេះដែរ មានបទបញ្ជាពីរាជរដ្ឋាភិបាលឱ្យរឹបអូសយកដីភ្នំ និងដីដែលទាក់ទងនឹងដីតំបន់ព្រៃឈើមកវិញ ដើម្បីធ្វើការដាំដុះដើមឈើឡើងវិញក្នុងគោលបំណងថែរក្សានិរន្តរភាពព្រៃឈើ ។

ឯកឧត្តម ប្រាជ្ញ ចន្ទ បន្តទៀតថា ៖ សព្វថ្ងៃអាជ្ញាធរខេត្តបាននឹងកំពុងសិក្សាលើការដាំកូនឈើនៅលើភ្នំក្នុងស្រុកទាំង ៤ និងព្រំដែនឡើងវិញ ( សំឡូត ភ្នំព្រឹក សំពៅលូន និងស្រុកកំរៀង ) និងធ្វើការពិគ្រោះស្នើសុំដល់ប្រជាពលរដ្ឋអោយផ្តល់ដីភ្នំមកវិញ និងពិសេសរដ្ឋបាលព្រៃឈើត្រូវត្រៀមកូនឈើសំរាប់ផ្តល់ដល់ការដាំឈើនេះអោយបានគ្រប់គ្រាន់ ។ អាជ្ញាធរខេត្តនឹងមានក្តីសង្ឃឹមថា បងប្អូនប្រជាពលរដ្ឋល្អនឹងរួមសហការជាមួយអាជ្ញាធរឃុំ ស្រុក និងគ្រប់សមត្ថកិច្ចទាំងអស់ រួមគ្នាថែរក្សា និងធ្វើការដាំកូនឈើនៅតាមភ្នំឡើងវិញ ។/